# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១០៦ អក-២០០១

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

លោកប្រធានតុលាការខេត្ត-ក្រុង

លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការសរសេរលិខិតទំនាក់ទំនងជាមួយស្ថានទូតនានាប្រចាំព្រះរាជាណាចក្រកម្ពុជា ។

**យោង:** លិខិតលេខ ៥៣៨ ចុះថ្ងៃទី០៧-០៨-០២០០០ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្តសៀមរាប ។

លិខិតលេខ ៥០១.ព្រ១.២០០០ ចុះថ្ងៃទី២៨-០៨-២០០០ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្តាល ។

ខ្ញុំសូមជម្រាបអស់លោកជ្រាបថា ក្រសួងបានទទួលលិខិតដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើរបស់លោកចៅក្រម និងលោកព្រះរាជអាជ្ញានៃខេត្ត-ក្រុងទាំងពីរដែលបានផ្ញើទៅឯកឧត្តមកុងស៊ុលកិត្តិយសប្រទេសស្វីស និងអគ្គរាជទូតចក្រភពអង់គ្លេស ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាហើយដែលបានចម្លងជូនក្រសួងយុត្តិធម៌ដើម្បីជ្រាបនោះ ឃើញថាពុំទាន់មានលក្ខណៈត្រឹមត្រូវតាមឋានានុក្រមនៃច្បាប់រដ្ឋបាល និងច្បាប់អន្តរជាតិឡើយ ។

ដូច្នេះអំណើះតទៅ ការសរសេរលិខិតទាក់ទងជាមួយស្ថានទូត ស្ថានឯអគ្គរាជទូត ស្ថានកុងស៊ុល ។ល។ អស់លោកត្រូវតែសរសេរទៅតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីក្រសួងផ្ញើលិខិតបញ្ជូនសំណូមពររបស់អស់លោកទៅរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃប្រទេសកម្ពុជា យើម្បីគោរពឱ្យបានត្រឹមត្រូវតាមឋានានុក្រមនៃច្បាប់រដ្ឋបាល និងច្បាប់អន្តរជាតិ ជៀសវាងការរំលោភលើអភ័យឯកសិទ្ធិរបស់ប្រទេសដែលបានដាក់ស្ថានឯកអគ្គរាជទូត ស្ថានទូ និងស្ថានកុងស៊ុលនៅប្រទេសកម្ពុជាយើង ។

ក្រសួងយុត្តិធម៌សង្ឃឹមថាអស់លោកនិងយកចិត្តទុកដាក់អនុវត្តតាមសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ជាពុំខាន ។

សូមអស់លោកទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០១

**រដ្ឋមន្ត្រី**

**អ៊ុក វិធុន**

<u>ចម្លងជូន</u>

-តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍

-ដើម្បីជ្រាប